ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៥៤ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៨

# ប្រកាស

## ស្ដីពី

## ការបង្កើត និងដាក់ឱ្យដំណើរការទីស្នាក់ការគយ និងរដ្ឋាករ ប្រចាំសន្និធិគយបណ្ដោះអាសន្ន ប៊ុក សេង ភីធី អេស អ៊ី ហ្សេត ប្រាយ ផត (ទីស្នាក់ការគយ និងរដ្ឋាករ ផែស្ងួត ប៊ុក សេង)

*** ៚ ***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្ដីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩២០ សហវ.ប្រក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីចាត់ការគយ និងរដ្ឋាករ
- បានឃើញប្រកាសលេខ ១០៦ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីសន្និធិគយបណ្ដោះអាសន្ន

- យោងកិច្ចសន្យាស្តីពីការបង្កើត និងធ្វើអាជីវកម្មសន្និធិគយបណ្តោះអាសន្ន (ផែស្ងួត) សំរាប់បញ្ចេញទំនិញពីគយ និងរដ្ឋាករ រវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងក្រុមហ៊ុន បុក សេង ភីភី អេស អ៊ី ហ្សេត ដ្រាយ ផត ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត បុក សេង ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ការិយាល័យគយ និងរដ្ឋាករផែស្ងួត នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ២.-**

ទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត បុក សេង ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៣.-**

ទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត បុក សេង មានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រង និងត្រួតពិនិត្យទំនិញក្នុងទីតាំងសន្និធិគយបណ្តោះអាសន្ន លើគ្រប់ទំនិញនាំចេញក្រៅក្របខ័ណ្ឌវិនិយោគ និងទំនិញនាំចូលគ្រប់ប្រភេទ លើកលែងតែមានការអនុញ្ញាតដោយឡែកពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- ចាត់តាំងក្រុមអនុរក្ស និងក្រុមត្រួតពិនិត្យលើកិច្ចប្រតិបត្តិការគ្រប់គ្រងទំនិញនាំចេញ នាំចូល ដែលស្ថិតនៅក្នុងសន្និធិគយបណ្តោះអាសន្ន បុក សេង លើទំនិញដូចចែងខាងលើ។
- ត្រួតពិនិត្យ និងប្រមូលពន្ធចំពោះមុខទំនិញនាំចូល នាំចេញដូចចែងខាងលើ និងអនុញ្ញាតឱ្យទំនិញចេញពីសន្និធិគយបណ្តោះអាសន្ន ក្រោយពីការត្រួតពិនិត្យ និងបញ្ចប់បែបបទគយតាមបទបញ្ញត្តិច្បាប់ជាធរមាន។
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៕/

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ